**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

លេខ ១៣៧/គ.ជ.ប
/០៨

# គោលការណ៍

## សម្រាប់

## អង្គការមិនមែនរដ្ឋាភិបាល និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ស្តីពីការរៀបចំ កម្មវិធីសំនួរចម្លើយ ឬពិភាក្សា អំពីគោលនយោបាយរបស់គណបក្សនយោបាយ ក្នុងពេលឃោសនាបោះឆ្នោត

- អនុលោមតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ ។
- អនុលោមតាមបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រជំពូកទី ៧ ស្តីពីការឃោសនាបោះឆ្នោត ។
- អនុលោមតាមគោលការណ៍សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ។
- ដើម្បីធានាឱ្យដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី ៤ ប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។
- ដើម្បីធានាឱ្យមានការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានស្របតាមគោលការណ៍ស្មើភាព ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចេញគោលការណ៍សម្រាប់អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននានា (ឬ**អ្នកគ្រប់គ្រងកម្មវិធី**) ដែលមានបំណងរៀបចំ**កម្មវិធីសំនួរចម្លើយ ឬពិភាក្សា** អំពីគោលនយោបាយគណបក្ស ដើម្បីផ្សព្វផ្សាយក្នុងពេលឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី ៤ ឆ្នាំ ២០០៨ ត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម ។

## ១. កិច្ចសហការជាមួយ គ.ជ.ប

### ១.១ ការពិគ្រោះយោបល់

អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននានា ដែលមានបំណងរៀបចំកម្មវិធីសំនួរចម្លើយ ឬពិភាក្សា អាចពិគ្រោះយោបល់ជាមួយគណៈកម្មការសម្របសម្រួលកម្មវិធីស្មើភាពរបស់ គ.ជ.ប មុននឹងចាប់ផ្តើមធ្វើកម្មវិធី លើបញ្ហាមួយចំនួនដូចជា ៖

- លក្ខណៈបច្ចេកទេសដែលត្រូវរៀបចំកម្មវិធី ។
- ប្រធានបទ ឬសំនួរ ដែលត្រូវដាក់ជូនគណបក្សនយោបាយ ដើម្បីចូលរួមក្នុងកម្មវិធី ។
- ការសម្របសម្រួលទីតាំងរៀបចំកម្មវិធី និងការការពារសន្តិសុខ សុវត្ថិភាព ។

### ១.២ ការទទួលខុសត្រូវ

- អ្នកគ្រប់គ្រងកម្មវិធី ត្រូវទទួលខុសត្រូវ លើខ្លឹមសារផ្សព្វផ្សាយគោលនយោបាយគណបក្ស ដែលបានផ្សព្វផ្សាយ ។
- រាល់ការចំណាយទាំងអស់ ជាបន្ទុករបស់អ្នកគ្រប់គ្រងកម្មវិធី ។



## ២. កិច្ចដំណើរការកម្មវិធី

**កម្មវិធីសំនួរចម្លើយ ឬពិភាក្សា** ត្រូវធ្វើឡើងជាមួយគណបក្សនយោបាយ ដែលបានទទួលការយល់ព្រមជាផ្លូវការដោយ គ.ជ.ប នូវការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ។ ដើម្បីឱ្យដំណើរការកម្មវិធីសំនួរចម្លើយ ឬពិភាក្សានេះ ប្រព្រឹត្តទៅតាមគោលការណ៍ស្មើភាពសម្រាប់គណបក្សនយោបាយ អ្នកគ្រប់គ្រងកម្មវិធីត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម ។

### ២.១ ការត្រៀមរៀបចំមុនកម្មវិធីចាប់ដំណើរការ

២.១.១ អ្នកគ្រប់គ្រងកម្មវិធី ត្រូវធ្វើលិខិតជាលាយលក្ខណ៍អក្សរអញ្ជើញគណបក្សនយោបាយទាំងអស់ ដែលបានទទួលការយល់ព្រមជាផ្លូវការដោយ គ.ជ.ប នូវការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ដើម្បីឱ្យចាត់តាំងតំណាងរបស់ខ្លួនចូលរួមក្នុងកម្មវិធីសំនួរចម្លើយ ឬពិភាក្សា ។

២.១.២ ករណីនៃការរៀបចំនៅថ្នាក់ខេត្ត ក្រុង ឬនៅថ្នាក់ជាតិ ការធ្វើលិខិតអញ្ជើញនេះ ត្រូវអញ្ជើញគ្រប់គណបក្សដែលមានបញ្ជីបេក្ខជនឈរឈ្មោះរបស់ខ្លួននៅក្នុងខេត្ត ក្រុងនោះ ឬអញ្ជើញគ្រប់គណបក្សនយោបាយទាំងអស់ ដែលមានបញ្ជីបេក្ខជនឈរឈ្មោះរបស់ខ្លួន នៅទូទាំង ២៤ ខេត្ត ក្រុង ។

២.១.៣ ក្នុងករណីអ្នកគ្រប់គ្រងកម្មវិធី រៀបចំកម្មវិធីនៅតាមខេត្ត ក្រុងច្រើន ត្រូវយកចិត្តទុកដាក់ធ្វើយ៉ាងណាឱ្យគ្រប់គណបក្សនយោបាយទាំងអស់ ដែលបានទទួលការយល់ព្រមជាផ្លូវការដោយ គ.ជ.ប នូវការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ បានចូលរួមក្នុងកម្មវិធីនោះ ។

២.១.៤ អ្នកគ្រប់គ្រងកម្មវិធីសំនួរចម្លើយ ឬពិភាក្សា ត្រូវផ្តល់ប្រធានបទ និងសំនួរ ដែលត្រូវចោទសួរក្នុងកម្មវិធីជូនគណបក្សនយោបាយយ៉ាងតិច ៧ ( ប្រាំពីរ ) ថ្ងៃ មុនថ្ងៃចាប់ផ្តើមកម្មវិធី ។

២.១.៥ ក្នុងករណីដែលគណបក្សនយោបាយបានទទួលលិខិតអញ្ជើញហើយ តែគណបក្សនយោបាយនោះពុំបានចាត់តំណាងរបស់ខ្លួនឱ្យមកចូលរួមក្នុងកម្មវិធីតាមកាលបរិច្ឆេទកំណត់ មានន័យថាគណបក្សនយោបាយនោះបោះបង់ចោលពេលវេលា និងឱកាសរបស់ខ្លួន ហើយកម្មវិធីនេះនឹងត្រូវដំណើរការធម្មតាទៅតាមកាលបរិច្ឆេទកំណត់ ។

## ២.២ ទីកន្លែងដំណើរការកម្មវិធី និងសមាសភាពចូលរួម

២.២.១ **កម្មវិធីសំនួរចម្លើយ ឬពិភាក្សា** អាចធ្វើនៅទីសាធារណៈ ឬទីកន្លែងបិទជិត នៅថ្នាក់ខេត្ត ក្រុង ឬថ្នាក់ជាតិ ។

២.២.២ **កម្មវិធីសំនួរចម្លើយ ឬពិភាក្សា** អាចធ្វើនៅនឹងស្ថានីយវិទ្យុ ឬទូរទស្សន៍ផ្ទាល់តែម្តង ។

២.២.៣ **កម្មវិធីសំនួរចម្លើយ ឬពិភាក្សា** អាចអញ្ជើញជាសាធារណៈឱ្យប្រជាពលរដ្ឋចូលរួមស្តាប់ និងចោទសំនួរដោយផ្ទាល់ ប្រសិនបើអ្នកគ្រប់គ្រងកម្មវិធីចង់ឱ្យមាន ។

## ២.៣ អ្នកសម្របសម្រួលកម្មវិធី

អ្នកសម្របសម្រួលកម្មវិធីសំនួរចម្លើយ ឬពិភាក្សា ត្រូវប្រកាន់ជំហរអព្យាក្រឹត យុត្តិធម៌ និងមានសមត្ថភាពក្នុងការគ្រប់គ្រងកិច្ចដំណើរការកម្មវិធីឱ្យបានល្អ និងសុវត្ថិភាព ។

## ២.៤ ការផ្សព្វផ្សាយ កម្មវិធីសំនួរចម្លើយ ឬកម្មវិធីពិភាក្សាតាមវិទ្យុ និងទូរទស្សន៍

កម្មវិធីសំនួរចម្លើយ ឬពិភាក្សា អំពីគោលនយោបាយរបស់គណបក្ស ដែលត្រូវផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ ត្រូវអនុវត្តដូចខាងក្រោម ៖

២.៤.១ **ការផ្សព្វផ្សាយថ្នាក់ខេត្ត ក្រុង** ៖ កម្មវិធីសំនួរចម្លើយ ឬពិភាក្សា ដែលធ្វើនៅតាមខេត្ត ក្រុង អាចធ្វើការផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ដែលមានស្ថានីយនៅក្នុងរង្វង់ខេត្ត ក្រុងនោះ ។

២.៤.២ **ការផ្សព្វផ្សាយថ្នាក់ជាតិ** ៖ កម្មវិធីសំនួរចម្លើយ ឬពិភាក្សា អាចផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍នៅថ្នាក់ជាតិបាន លុះត្រាតែមានការចូលរួមគ្រប់គណបក្សនយោបាយទាំងអស់ ដែលបានទទួលការយល់ព្រមជាផ្លូវការដោយ គ.ជ.ប នូវការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ។

## ៣. គោលការណ៍ច្បាប់

៣.១ អ្នកគ្រប់គ្រងកម្មវិធីសំនួរចម្លើយ ឬពិភាក្សា អាចផ្តល់ម៉ោងដល់គណបក្សនយោបាយក្នុងការឆ្លើយសំនួរ ផ្អែកតាមគោលការណ៍ស្មើភាព លំដាប់មុនក្រោយ ។

៣.២ អ្នកគ្រប់គ្រងកម្មវិធីសំនួរចម្លើយ ឬពិភាក្សា អំពីគោលនយោបាយរបស់គណបក្ស ត្រូវតែអព្យាក្រឹត និងមិនលម្អៀង ។

៣.៣ ការផ្សព្វផ្សាយកម្មវិធីសំនួរចម្លើយ ឬពិភាក្សា អំពីគោលនយោបាយគណបក្ស ពុំតម្រូវឱ្យមានលិខិតយល់ព្រមពី គ.ជ.ប ឡើយ ។ ប៉ុន្តែអ្នកគ្រប់គ្រងកម្មវិធីនេះត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ក្នុងករណីមានកំហុសលើដំណើរការនៃការផ្សាយកម្មវិធី ។

៣.៤ កម្មវិធីសំនួរចម្លើយ ឬពិភាក្សា ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ តែក្នុងអំឡុងពេលនៃការឃោសនាបោះឆ្នោតប៉ុណ្ណោះ ។ ការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី ៤ ចាប់ផ្តើមពីថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០៨ ដល់ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០៨ ។

៣.៥ អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ឬអ្នកគ្រប់គ្រងកម្មវិធីសំនួរចម្លើយ ឬពិភាក្សា ត្រូវបញ្ឈប់ទាំងស្រុង គ្រប់សកម្មភាពទាំងអស់ដែលទាក់ទងដល់ការឃោសនាបោះឆ្នោតក្នុងរយៈពេល ២៤ (ម្ភៃបួន) ម៉ោង មុនថ្ងៃបោះឆ្នោត និងថ្ងៃបោះឆ្នោត ។ ក្នុងករណីប្រព្រឹត្តល្មើសនឹងត្រូវទទួលពិន័យ តាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

ភ្នំពេញ ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៨

ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ប្រធាន

អ៊ឹម សួស្តី